# សេចក្តីអំពាវនាវ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ

## វត្តខ្មែរកាណាដា សុំឲ្យខ្មែរឈប់ប្រើអំពើហឹង្សា

**Website: www.hoksavann.org**

ថ្ងៃទី៥ កញ្ញា ២០០៤

ជិតពីរពាន់ឆ្នាំ ប្រទេសកម្ពុជាជាប្រទេសគោរពព្រះពុទ្ធសាសនា, ក្នុងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ជាគោលសំខាន់គឺធម៌អហឹង្សា ។ ដោយគោរពតាមព្រះពុទ្ធ ជាធម៌សន្តិភាពរបស់ពុទ្ធសាសនិកជនខ្មែរ បានធ្វើឲ្យចរឹតលក្ខណៈជនជាតិខ្មែរទន់ភ្លន់សុភាពរាបសារ ស្គាល់បាបបុណ្យគុណទោសអាក្រក់ល្អ ស្គាល់ម្តាយឪពុក ស្គាល់ចាស់ទុំ ស្គាល់ហេតុល្អហេតុអាក្រក់ គួរធ្វើមិនគួរធ្វើ តាំងពីបូរាណកាលមក ។ ប៉ុន្តែគួរស្តាយក្នុងរវាង ២០, ៣០ឆ្នាំ លក្ខណៈនេះបានត្រូវចុះខ្សោយដោយសារសង្គ្រាមទាស់ទែងខ្វែងគំនិតគ្នា ។

អំពើហឹង្សា ការបៀតបៀនគ្រប់ប្រភេទ បានកើតឡើងជាបន្តបន្ទាប់គ្នា ដោយមូលហេតុផ្សេងៗគ្នា ។ ការធ្វើសង្គ្រាមកាប់សម្លាប់គ្នា ។ ការកាប់សម្លាប់ប្រជាពលរដ្ឋខ្មែររាប់លាននាក់របស់ខ្មែរក្រហម ។ ដោយសារការអប់រំតាមរបៀបកុម្មុយនិស្ត ខ្មែរក្រហមឲ្យខ្មែរចងគំនុំសងសឹកគ្នា ដែលលទ្ធិនេះហៅថារ៉ាយរបបសក្តិភូមិមូលធននិងចក្រពត្តិ បានជះឥទ្ធិពលអាក្រក់រហូតមកដល់សព្វថ្ងៃ ។ ការលួចសម្លាប់គ្នា ដោយផ្លូវនយោបាយនិងមិនមែនផ្លូវនយោបាយ ។ ការចាក់ទឹកអាស៊ីដដាក់គ្នា ដោយការច្រណែនគ្នារវាងប្រពន្ធចុងនិងប្រពន្ធដើម ។ ការវាយសម្លាប់មនុស្ស ដែលគេចោទថាជាចោរ ដោយដំបង ដោយគប់ដុំថ្ម ដោយពុំទុកចិត្តប្រព័ន្ធតុលាការខ្មែរ ។

អំពើអមនុស្សធម៌ទាំងនោះ នាំឲ្យប្រទេសកម្ពុជាដែលជាប្រទេសធ្លាប់រស់នៅសុខសាន្ត ទៅជាប្រទេសរស់នៅដោយការភិតភ័យ ។ តាមផ្លូវព្រះពុទ្ធសាសនា ការប្រើធម៌ហឹង្សាបៀតបៀនគ្នា រហូតដល់សម្លាប់គ្នានេះ ដោយការចង់យកឈ្នះចាញ់គ្នា ដោយការច្រណែនឈ្នានិសគ្នា ដោយសេចក្តីលោភលន់ ខ្វះសេចក្តីសន្តោស គ្មានធម៌មេត្តានិងយល់ខុសថា មធ្យោបាយប្រើហឹង្សានេះ អាចយកជ័យជំនះពីគូប្រជែងឬគូសត្រូវបាន ។ យ៉ាងណាមិញការយកឈ្នះចាញ់គ្នាខាងផ្លូវនយោបាយ គេកម្រឃើញប្រទេសដទៃប្រើហឹង្សាលួចសម្លាប់គ្នាដូចប្រទេសកម្ពុជា ដែលអ្នកសង្កេតការណ៍យល់ថា មួយភាគកើតចេញមកពីផ្លូវនយោបាយ ព្រោះអ្នកស្លាប់មានអ្នកសារពត៌មាន បញ្ញវ័ន្ត និងឥស្សរជនមានប្រជាប្រិយ៍ និងគណបក្សប្រឆាំង ។ ប្រទេសដែលកាន់របបប្រជាធិបតេយ្យទាំងនោះ គេយកឈ្នះចាញ់គ្នា ដោយធ្វើការងារបំរើជាតិដោយស្មោះត្រង់ ដើម្បីជាតិមានសន្តិភាព, វឌ្ឍនភាព និងយុត្តិធម៌ ។ កាលណារដ្ឋាភិបាលធ្វើការបានល្អហើយ ប្រជាពលរដ្ឋនឹងបោះឆ្នោតឲ្យនៅអាណត្តិក្រោយទៀត ។ គឺការយកឈ្នះគ្នាដោយការងារល្អ គេមិនប្រើអំពើហឹង្សា ការបៀតបៀនគ្នាឡើយ ។ ការអនុវត្តន៍របស់គេបែបនេះ ត្រូវគ្នានឹងធម៌ព្រះពុទ្ធដែរ ។ ការជះទឹកអាស៊ីដដាក់គ្នា មូលហេតុមកអំពីប្តីចេះតែមានប្រពន្ធចុង ។ ការសម្លាប់មនុស្សក្រៅច្បាប់ ដែលចោទថាជាចោរ មកអំពីពុំជឿប្រព័ន្ធតុលាការខ្មែរ ដែលគេចោទថាពុករលួយ ប្រកាន់បក្សពួក មិងមានឥទ្ធិពលពីអ្នកកាន់អំណាច ។ ការលួច ការប្លន់ រហូតមានការកាប់សម្លាប់ ដោយសារតែភាពក្រីក្រនិងខ្វះសីលធម៌ ។ អំពើហឹង្សាម៉្យាងទៀត កើតមកអំពីអំពើអបាយមុខ ល្បែងស្រី ល្បែងស្រា និង ល្បែងស៊ីសង ។

សូមអំពាវនាវជនជាតិខ្មែរគ្រប់ឋានៈ ដែលបានប្រើអំពើហឹង្សា សូមឈប់ប្រើអំពើនេះតទៅទៀត ចំណែកជនជាតិខ្មែរច្រើនលើសលប់ជាអ្នកស្លូតត្រង់សុភាពរាបសារ សូមរក្សាចរិយាដ៏ល្អនេះឲ្យស្ថិតនៅជានិច្ច ។ ការប្រើអំពើហឹង្សានេះ មិនត្រឹមតែនាំបុគ្គលអ្នកប្រព្រឹត្ត ឲ្យទទួលទុក្ខប៉ុណ្ណោះទេ ថែមទាំងនាំឲ្យប្រទេសរបស់ខ្លួនខូចឈ្មោះ ខូចកិត្តិយសថែមទៀត ។ អំពីប្រជាពលរដ្ឋប្រើអំពើហឹង្សា ពីបុគ្គលម្នាក់ទៅម្នាក់ពុំសូវជាធ្ងន់ទេ ព្រោះគេអាចបំបាត់បាន ប៉ុន្តែបើអ្នកនយោបាយ អ្នកដឹកនាំប្រើអំពើហឹង្សាទៅលើប្រជាពលរដ្ឋរបស់ខ្លួនវិញ ជាបញ្ហាធ្ងន់ណាស់ ពិបាកបំបាត់ណាស់ ព្រោះគេមានអំណាច រហូតដល់គេប្រើអំពើហឹង្សា ប្រើអាវុធសំរាប់បង្ក្រាបអ្នករិះគន់អ្នកប្រឆាំងថែមទៀត ។ ឧទាហរណ៍ខ្មែរក្រហមសម្លាប់ប្រជាពលរដ្ឋរបស់ខ្លួនរាប់លាននាក់ មានភស្តុតាងគ្រប់គ្រាន់ រហូតមកទល់ពេលនេះ គ្មានអ្នកណាធ្វើអ្វីខ្មែរក្រហមបានឡើយ ។ នៅពេលនេះទៀត អ្នកសារពត៌មាន បញ្ញវ័ន្ត ឥស្សរជនអ្នកមានប្រជាប្រិយ៍ និងសកម្មជនបក្សប្រឆាំងត្រូវគេសម្លាប់ ក៏ពុំដែលរកមុខឃើញមកផ្តន្ទាទោសឡើយ ។ នៅបច្ចុប្បន្ននេះទៀត ប៉ូលិសកងអាវុធហត្ថ ឃើញតែដើរបង្ក្រាបវាយដំប្រជាពលរដ្ឋ ដោយចុងកាំភ្លើង ដោយដំបងឆក់ រហូតដល់បាញ់គំរាមកំហែងប្រជាពលរដ្ឋ ដែលធ្វើបាតុកម្មប្រឆាំងនឹងក្រុមហ៊ុនទុច្ចរិត ដែលរំលោភលើសិទ្ធិរបស់ខ្លួនជាកម្មករ ប្រឆាំងនឹងអ្នកកាន់អំណាចរំលោភយកទឹកដីពីខ្លួន ប្រឆាំងពីប្រេងសាំងឡើងថ្លៃជាដើម ។ អាជ្ញាធរមានសមត្ថកិច្ច ប៉ូលិស ពុំបំរើផលប្រយោជន៍ប្រជាពលរដ្ឋ ដោយតាមការពារសន្តិសុខទេ បែរជាការពារជនទុច្ចរឹតទៅវិញ ជាពិសេសសាលាក្រុងភ្នំពេញ ។

ដើម្បីបំបាត់អំពើហឹង្សារបស់អ្នកកាន់អំណាចមកលើប្រជាពលរដ្ឋរបស់ខ្លួន មានតែពង្រឹងប្រព័ន្ធច្បាប់ ពង្រឹងប្រព័ន្ធតុលាការឲ្យឯករាជ្យ ហើយជនណាដែលប្រព្រឹត្តខុស ទោះបីជននោះមានបុណ្យស័ក្តិខ្ពស់យ៉ាងណាក៏ដោយ ក៏ត្រូវតែនាំឡើងតុលាការកាត់ទោស ។ នេះវិធានការតាមផ្លូវច្បាប់ក្នុងផ្លូវអាណាចក្រ ។ បើដំណោះស្រាយតាមពុទ្ធចក្រវិញ បើគេជឿពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺព្រះពុទ្ធរំលឹកហើយរំលឹកទៀតចំពោះជនទូទៅថា បើអ្នកចង់ឲ្យគេស្រឡាញ់រាប់អាន ចង់ឲ្យគេគោរព ចង់ឲ្យគេគាំទ្រ រូបមន្តមានតែមួយគឺអ្នកត្រូវសាងល្អ (កុសលាធម្មា) ដោយកុំសាងអាក្រក់ (អកុសលាធម្មា) ដោយកិរិយាមិនតិះដៀល កិរិយាមិនបៀតបៀន (អនូបវាទោ អនូបឃាតោ) អ្នកដទៃ ។ បើអ្នកដឹកនាំត្រូវគោរពតាមមុខងារនាទីរបស់ខ្លួនជាអ្នកដឹកនាំ គឺនាយកធម៌ ។ ដើម្បីបំបាត់ការជះទឹកអាស៊ីដដាក់គ្នា បុរសនិងស្ត្រីប្តីប្រពន្ធ ត្រូវគោរពតាមសិក្ខាបទទីបីនៃសីល៥គឺ កាមេសុមិច្ឆាចារៈ វៀរចាកការប្រព្រឹត្តខុសក្នុងកាម គឺកុំទៅរំលោភប្រពន្ធប្តីកូនអ្នកដទៃ ។ ប្តីប្រពន្ធត្រូវស្មោះត្រង់នឹងគ្នា មួយនិងមួយ កុំក្បត់ចិត្តគ្នា បើប្តីកុំទៅយកស្រីដទៃ ។ អាជ្ញាធរខ្មែរត្រូវបិទស្រីបនទាំងអស់ ព្រោះការមានស្រីបននេះហើយ ដែលនាំឲ្យបុរសជាប្តីទៅប្រព្រឹត្តល្បែងស្រី ដែលនាំឲ្យស្ត្រីប្រពន្ធដើមប្រច័ណ្ឌ ជំរុញរហូតជះទឹកអាស៊ីដដាក់គ្នា ហើយជាប្រភពនាំឲ្យកើតរោគអេដ៍ទៀតផង ។ ដើម្បីបំបាត់បញ្ហាការសម្លាប់មនុស្ស ដែលចោទថាជាចោរ ត្រូវពង្រឹងប្រព័ន្ធតុលាការឲ្យការកាត់សេចក្តីមានយុត្តិធម៌ វៀរចាកការកាត់សេចក្តីដោយអគតិធម៌ គឺ

ការកាត់សេចក្តីដោយលំអៀងតាមព្រះពុទ្ធសំដែង គឺកុំកាត់សេចក្តីលំអៀង ព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះភ័យខ្លាច និងព្រោះល្ងង់ពុំដឹងការពិតឡើយ ។ ស្ថាប័នតុលាការត្រូវស្ថិតនៅឯករាជ្យ ហើយកុំស៊ីសំណូកពុករលួយ ។ បើតុលាការបានធ្វើឲ្យប្រជាពលរដ្ឋទុកចិត្តហើយ ការសម្លាប់មនុស្សក្រៅច្បាប់ ដែលចោរថាជាចោរនឹងត្រូវអន់ថយឬបាត់តែម្តង ។ ការបំបាត់ចោរលួចចោរប្លន់ ជាដំបូងរដ្ឋត្រូវដោះស្រាយឲ្យប្រជាពលរដ្ឋមានជីវភាពខ្ពស់ ដោយបំបាត់ភាពក្រីក្រកុំឲ្យកើតមាន ។ ក្រៅពីនោះ ប្រជាពលរដ្ឋនាំគ្នាសិក្សានិងអនុវត្តតាមសិក្ខាបទទី២នៃសីល៥ គឺ អទិន្នាទាន កុំលួចកុំប្លន់ដោយខ្លួនឯង ឬប្រើគេឲ្យលួចប្លន់ ព្រោះជាអំពើពុំល្អ កាលណាគេចាប់បាន ត្រូវជាប់ទោសតាមច្បាប់របស់រដ្ឋ ហើយនិងត្រូវមានទោសនៅអនាគតជាតិទៀត ។

ដូចបានពោលមកហើយ ដើម្បីឲ្យប្រទេសកម្ពុជាមានសន្តិភាពនិងវឌ្ឍនភាព ត្រូវតែកំចាត់អំពើហឹង្សាផ្នែកអ្នកនយោបាយ និងហឹង្សាផ្នែកប្រជាពលរដ្ឋ ។ អ្នកនយោបាយខ្មែរនិងប្រជាពលរដ្ឋ គប្បីក្រឡេកមើលប្រទេសដែលមានអារ្យធម៌ខ្ពស់ គេគោរពសិទ្ធិគ្នាទៅវិញទៅមកល្អណាស់ ហើយគេចេះអត់ឱនឲ្យដល់គ្នា នូវកំហុសបន្តិចបន្តួចដែលកើតឡើងដោយអចេតនា ដូចដើរទៅប៉ះគ្នា គេគ្រាន់តែពោលថាសុំទោស អ្នកដែលត្រូវគេប៉ះក៏ពោលតបវិញថា មិនអីទេ គ្មានបញ្ហាអ្វីទេ ។ ពីដើមខ្មែរយើងក៏មានលក្ខណៈដូចគ្នាដែរ ។ ប៉ុន្តែបច្ចុប្បន្ននេះ សុជីវធម៌បែបនេះហាក់ដូចជាធ្លាក់ចុះ ឧទាហរណ៍នៅភ្នំពេញ មានកូនអ្នកធំអ្នកមានអំណាចម្នាក់ គ្រាន់តែកូនអ្នកក្រជិះម៉ូតូប៉ះទឹកសាចទៅប៉ះរថយន្តរបស់ខ្លួនកូនអ្នកធំនោះមានកំហឹង ក៏លើកកាំភ្លើងបាញ់តម្រង់ទៅកូនអ្នកក្រពីរនាក់ដែលជិះម៉ូតូនោះ គ្រាប់បែកបានទៅប៉ះកូនអ្នកក្រម្នាក់ស្លាប់ កូនអ្នកធំនោះក៏បររថយន្តគេចខ្លួនបាត់ទៅ ។ នេះគ្រាន់តែសាចទឹកប៉ះរថយន្តដោយអចេតនា គួរតែពិចារណាឲ្យមានការអត់ឱន ទៅជាបង្កើតកំហឹងរហូតដល់ថ្នាក់បាញ់សម្លាប់មនុស្សបែបនេះ ។ នេះជាអំពើរបស់កូនអ្នកធំអ្នកមានអំណាច ហើយអ្នករងគ្រោះក៏គ្មានអាជ្ញាធរណាស្វែងរកឃាតករនេះយកទៅផ្តន្ទាទោសឡើយ ។

ដើម្បីបន្ថយអំពើហឹង្សាទាំងនេះ ក្រៅពីការគោរពច្បាប់របស់ប្រទេសនិងច្បាប់អន្តរជាតិ ជនជាតិខ្មែរគ្រប់ឋានៈនាំគ្នាសិក្សាច្បាប់ក្បួនព្រះពុទ្ធសាសនា ហើយយកមកអប់រំខ្លួន ។ ព្រះពុទ្ធបង្រៀនឲ្យស្រឡាញ់ខ្លួនឯង ប៉ុន្តែមិនត្រូវបៀតបៀនអ្នកដទៃឡើយ ដោយព្រះអង្គឲ្យប្រៀបធៀបខ្លួនយើងទៅនឹងអ្នកដទៃថា ខ្លួនយើងស្រឡាញ់ជីវិតស្រឡាញ់កូនចៅក្រុមគ្រួសារយ៉ាងណា មនុស្សដទៃទៀតក៏ស្រឡាញ់ដូចគ្នាដែរ ដូច្នេះពុំត្រូវបៀតបៀនគ្នាឡើយ ។ សេចក្តីសុខកើតចេញមកពីការមិនបៀតបៀនគ្នា ដែលជាគោលធំរបស់ព្រះពុទ្ធសាសនា បានដល់ធម៌អហឹង្សានេះឯង ៕៚